# ស្លាប់ហើយកើតយ៉ាងម៉េច?

ក្នុងព្រះត្រៃបិដក មានចម្លើយជាច្រើនដែលមានទាក់ទងជាមួយនឹងសំនួរថា " ស្លាប់ហើយកើតយ៉ាងម៉េច?" នឹងស្រង់យកមកនិយាយខ្លះដូចមានតទៅនេះ:

១-ក្នុងមិលិន្ទបញ្ហា មាននិយាយយ៉ាងខ្លីថា " នាមរូប" បានធ្វើកុសលនិងអកុសល ។ កម្មទាំងអស់នេះជាហេតុឱ្យកើតនាមរូបថ្មីឡើងទៀត។

២-ក្នុងមហាតណ្ហាសង្ខយសូត្រនៃមជ្ឈិមនិកាយ មានសេចក្តីបញ្ជាក់យ៉ាងច្បាស់ថា: សត្វដែលកើតឡើងបានត្រូវប្រកបដោយ:

**ក** - បិតានិងមាតាបានរួមសេវនៈកិច្ច ;

**ខ** - មាតាកំពុងមានរដូវបរិបូណ៌ ;

**គ** - មានគន្ធព្វសត្វ ( សត្វចាប់ផ្ទៃ ) ទើបជីវិតអាចកើតឡើងបាន។

៣-ក្នុងមហានិព្វានសូត្រនៃទីឃនិកាយព្រះបរមសាស្តាចារ្យរបស់យើង ទ្រង់បានធ្វើសេចក្តីអធិប្បាយអំពីបដិច្ចសមុប្បាទ ឱ្យអានន្ទស្តាប់ មានសេចក្តីក្នុងចំណុចថា " បើវិញ្ញាណមិនចូលកាន់ផង់កូននៃមាតា នាមរូបនឹងកើតយ៉ាងម៉េចបាន បើវិញ្ញាណដែលហូរចូលទៅកាន់សំបុកកូនមាតានោះ ត្រឡប់ដកខ្លួនចេញមកវិញកូនក្នុងគភ៌នោះនឹងចំរើនធំធាត់បានយ៉ាងណា"។

៤-ក្នុងបាយាសិសូត្រនៃទីឃនិកាយមានសេចក្តីមួយអន្លើថា: មនុស្សយើងត្រូវមានការអប់កំដៅ ទើបវិញ្ញាណអាចនឹងតាំងនៅបាន។

៥-ក្នុងកេវដ្តសូត្រនៃទីឃនិកាយព្រះបរមគ្រូទ្រង់តាំងសំនួរថា: ដី, ទឹក, ភ្លើង, ខ្យល់, រលត់ក្នុងទីណា? ទ្រង់តបសំនួររបស់ព្រះអង្គថា: រលត់ក្នុងទីព្រះនិព្វាន ដោយអត្ថថា វិញ្ញាណក្នុងគ្រប់ជីវិតទាំងអស់ ត្រូវរលត់សូន្យទៅ

មិនមានកម្មបញ្ជូនឱ្យ ទៅកើតថ្មីក្នុងទីណាទៀត ទើបមានឈ្មោះសម្រេចព្រះនិព្វាន។

**៦**-ក្នុងអច្ឆរិយពុទ្ធធម្មសូត្រនៃមជ្ឈិមនិកាយ ព្រះអានន្ទបានពោលដល់រឿងព្រះសម្ពុទ្ធថា: ព្រះពុទ្ធអង្គទ្រង់បានជ្រាបថា: មុននឹងចូលកាន់ផ្ទៃព្រះមាតា ព្រះអង្គទ្រង់ធ្លាប់កើតក្នុងសួគ៌វិមាន។ ដូច្នេះ ឃើញថាសត្វដែលនឹងអាចកើតឡើងបាន ត្រូវមានវិញ្ញាណទើបកើតបាន។

តាមសូត្រដែលពោលមកខាងលើនេះទាំងប៉ុន្មាន មានសេចក្ដីល្មមឱ្យយើងសន្និដ្ឋានប្រកបដោយហេតុផលថា: មនុស្សយើងស្លាប់ហើយត្រូវកើតទៀតយ៉ាងម៉េចនោះហើយ

ម្យ៉ាងទៀត យើងបានដឹងចាកមិលិន្ទបញ្ហានិងសូត្រដទៃទៀតថា: " វិញ្ញាណរបស់សត្វដែលនឹងមកកើតនោះ មិនមែនជាវិញ្ញាណក្នុងជីវិតមុនៗ ដោយដាច់ខាត ព្រោះព្រះពុទ្ធអង្គទ្រង់បានដៅបញ្ជាក់រឿយៗថា: ខន្ធ ៥ រលត់ទៅវាល់ខណៈដែលជីវិតត្រូវរលត់។ ដោយហេតុនេះវិញ្ញាណរបស់សត្វដែលនឹងមកកើតនោះ ត្រូវជាវិញ្ញាណមួយថ្មី ដែលកើតមកអំពីកម្មចាស់គឺកើតក្នុងខ្លួនរបស់អ្នកដែលនឹងមកកើតនុ៎ះឯង។ វាជាធាតុកើតចាកអវិជ្ជានិងតណ្ហា ដែលមានមកជាមួយនឹងកម្មចាស់សឹងជាហេតុនៃសេចក្ដីទុក្ខនិងសេចក្ដីអន្ទោលកើយស្លាប់ដែលបាននិយាយមកហើយ។

វិញ្ញាណរបស់សត្វដែលនឹងមកកើតនោះ ផ្សេងពីវិញ្ញាណដែលធ្លាប់មានមកពីក្នុងកាលមុន គឺវិញ្ញាណនេះមានលក្ខណៈសមសួននិងសំណល់របស់កម្មដែលខ្លួនបានកសាងមកនុ៎ះឯង។ វិញ្ញាណនុ៎ះហើយ ដែលចូលមកនៅក្នុងថង់កូនរបស់មាតា

ហើយសាងនាមរូបឡើងជាថ្មីទៀត។

ចម្លងចេញពីសៀវភៅ ជីវិតសន្តិភាព ទំព័រ៨៤

ព.ស. ២៥១៤ គ.ស. ១៩៧០

រៀបរៀងដោយភិក្ខុ ធម្មបាល ខៀវ-ជុំ វត្តលង្កាភ្នំពេញបោះពុម្ពសាឡើងវិញនៅ គ.ស. ២០០១

ចម្លងដោយខ្ញុំបាទ វ៉ាន់-អ៊ុង អាចារ្យទី១ សម្រាប់បំរើនូវកិច្ចការផ្សេងៗ នៃ វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ចម្លងចប់ នៅថ្ងៃពុធ ១កើតខែកត្តិក ឆ្នាំរោងចត្វាស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា គ.ស.២០១២

វាយចម្លងដាក់គេហទំព័រវត្តដោយខ្ញុំបាទ អ៊ិន ឈី ថ្ងៃទី៤ ខែកក្កដា គ.ស. ២០១៣□